គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី
Active People's Microfinance Institution Plc.

# របាយការណ៍ប្រចាំឆ្នាំ ២០២៥
# ANNUAL REPORT 2025




គ្រឹះស្ថានឯកជន/ Private Company

# មាតិកា

**១. សាររបស់អគ្គនាយក**......១
**២. អំពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេក់ទីវ ភីភល ភីអិលស៊ី**......៣
២.១. ប្រវត្តិសង្ខេប......៣
២.២. ចក្ខុវិស័យ បេសកកម្ម ពាក្យស្លោក ក្រមអនុវត្ត គោលការណ៍ណែនាំ......៥
២.៣. ផលិតផល និងសេវាកម្ម......៧
២.៤. បណ្តាញប្រតិបត្តិការ......៨
ក. ផលប័ត្រឥណទានសរុប (ដុល្លារអាមេរិក)......៨
ខ. ចំនួនអតិថិជន......៨
គ. ទីស្នាក់ការ និងសាខាធ្វើប្រតិបត្តិការរបស់គ្រឹះស្ថាន......៩
**៣.អភិបាលកិច្ចសាជីវកម្ម**......១០
៣.១. រចនាសម្ព័ន្ធ......១០
៣.២.ក្រុមប្រឹក្សាភិបាល......១២
៣.៣.គណៈគ្រប់គ្រងជាន់ខ្ពស់......១៣
៣.៤.គណៈគ្រប់គ្រងនាយកដ្ឋានប្រត្តិបត្តិការ......១៤
**៤. សកម្មភាពសង្គម អប់រំ កីឡា និងសកម្មភាពផ្សេងៗ**......១៥
ក. សកម្មភាពមនុស្សធម៌ កាកបាទក្រហមកម្ពុជា......១៥
ខ. ការបរិច្ចាគឈាម......១៥
គ. ការបរិច្ចាគដល់ជនភៀសសឹក......១៦
ឃ. ការប្រកួតជើងឯក អត្តពលកម្មជនពិការ លើកទី៦ ឆ្នាំ២០២៥......១៦
ង. កម្មវិធីប្រគល់រង្វាន់ជូនអតិថិជន......១៧
ច. កម្មវិធីលៀងសាយភោជន......១៧
ឆ. ការប្រកួតកីឡាប្រចាំឆ្នាំ......១៨
ជ. កម្មវិធីជប់លៀងបុគ្គលិកប្រចាំឆ្នាំ......១៨
ឈ. ពានរង្វាន់ **“The Next Global 100 Awards 2025”**......១៩

# ១. សាររបស់អគ្គនាយក




ភាគីពាក់ព័ន្ធទាំងអស់ជាទីគោរព!

អស់រយៈពេលជាង៥ឆ្នាំកន្លងទៅនេះសេដ្ឋកិច្ចពិភពលោកហាក់មានការធ្លាក់ចុះនិងងើបឡើងបន្តិចម្តងៗ។ បញ្ហាជំងឺរាតត្បាតដោយ កូវីដ ១៩ បានរសាយបាត់ទៅ មិនបានប៉ុន្មានឆ្នាំ បញ្ហាសង្គ្រាមបានគម្រាមកំហែងដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ។ យ៉ាងណាមិញ ប្រទេសកម្ពុជានាពេលចុងឆ្នាំ២០២៥ បានទទួលរងផលប៉ះពាល់ខ្លាំងនៅតំបន់ព្រំដែន ដោយសារជម្លោះដោយប្រដាប់អាវុធនិងការបិទច្រកព្រំដែនទាំងស្រុងរវាងកម្ពុជាថៃជាកត្តាមួយដ៏ធំដែលធ្វើឱ្យមានផលប៉ះពាល់ដល់វិស័យផ្សេងៗ រួមទាំងវិស័យធនាគារ និងហិរញ្ញវត្ថុផងដែរ។ ក្នុងនាមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានអាយុកាលជាង១០ឆ្នាំក្នុងការឈរជើងឆ្លងកាត់ឧបសគ្គនិងស្ថានភាពលំបាកជាច្រើននៅប្រទេសកម្ពុជា គ្រឹះស្ថាននៅតែបន្តចក្ខុវិស័យរបស់ខ្លួនក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេនៅកម្ពុជា។

ក្នុងបេសកកម្មយ៉ាងស្វាហាប់របស់យើង ក្នុងការជួយជំរុញការផ្តល់ឥណទាន ដើម្បីបង្កើនជីវភាពប្រជាជនកម្ពុជាគ្រឹះស្ថានមិនរុញរាក្នុងការចូលរួមយ៉ាងសកម្មជាមួយធនាគារជាតិនៃកម្ពុជានិងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដើម្បីសហការយ៉ាងរឹងមាំគ្រប់ស្ថានភាពក្នុងគោលជំហរបង្កើនភាពធនដល់វិស័យទាំងមូល។ ដោយឡែកសកម្មភាពមនុស្សធម៌ផ្សេងៗ គ្រឹះស្ថាននៅតែបន្តចូលរួមដូចជា ការចូលរួមបរិច្ចាគជាថវិការ ជូនកាកបាទក្រហមកម្ពុជា ការបរិច្ចាគឈាមដើម្បីសង្គ្រោះជីវិត ការបរិច្ចាគថវិកា និងសម្ភារជូនអត្តពលកម្មជនពិការផងដែរ។

លទ្ធផលរបាយការណ៍ហិរញ្ញវត្ថុក្នុងឆ្នាំ២០២៥ គឺជាទឡ្ហីករណ៍បញ្ជាក់ពីកំណើនប្រកបដោយភាពធននិងជាយុទ្ធសាស្ត្ររបស់យើង។ ទ្រព្យសកម្មរបស់គ្រឹះស្ថានកើនឡើងបានចំនួន ១០,២៦% បើប្រៀបធៀបទៅនឹងឆ្នាំ២០២៤ ដែលសម្រេចឈានដល់ ៥៦៣.៦៣៨.១៩៧ ដុល្លារអាមេរិក។

ដោយមានការគាំទ្រសេវាកម្មឥណទានពីសំណាក់អតិថិជន នៅចុងឆ្នាំ២០២៥ គ្រឹះស្ថានបានទទួលអាជ្ញាបណ្ណសាខាថ្មី ចំនួនពីរបន្ថែមទៀត មានទីតាំងនៅក្នុងខេត្តព្រះសីហនុ និងខេត្តពោធិ៍សាត់ ដើម្បីពង្រីកតំបន់ប្រតិបត្តិការរបស់ខ្លួនទៅកាន់អតិថិជនឱ្យកាន់តែរហ័សទាន់ចិត្ត។ ក្នុងឆ្នាំ២០២៥ គ្រឹះស្ថានមានទីតាំងសរុបចំនួន ៣១ សាខាខេត្ត ក្រុង និងស្រុក។ ការរីកចម្រើននេះគឺបានមកពីការជឿទុកចិត្តពីសំណាក់អតិថិជនគ្រប់រូប និងការខិតខំប្រឹងប្រែងរបស់បុគ្គលិកគ្រប់ជាន់ថ្នាក់។

ជាថ្មីម្តងទៀត ខ្ញុំបាទជំនួសមុខឱ្យក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំជាន់ខ្ពស់របស់គ្រឹះស្ថានសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈគ្រប់គ្រង និងបុគ្គលិករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ទាំងអស់ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការបំពេញតួនាទីភារកិច្ចរៀងៗខ្លួនបានយ៉ាងល្អរហូតទទួលលទ្ធផលល្អ។សូមឱ្យការព្យាយាមប្រឹងប្រែងនេះនៅតែបន្តដើម្បីផ្តល់សេវាកម្មដ៏ល្អប្រសើរជូនដល់អតិថិជនគ្រប់ៗគ្នា។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំបាទសូមថ្លែងអំណរគុណផងដែរចំពោះ ភាគទុនិក ក្រុមប្រឹក្សាភិបាល អតិថិជន រាជរដ្ឋាភិបាល ជាពិសេសធនាគារជាតិនៃកម្ពុជាដែលតែងតែគាំទ្រ និងផ្តល់អនុសាសន៍ល្អៗជារៀងរហូតមក ដល់គ្រឹះស្ថានយើងខ្ញុំ។

**Nobuhito KIKUCHI**

**សមាជិកក្រុមប្រឹក្សាភិបាល/អគ្គនាយក**

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ ភីភល ភីអិលស៊ី**

# ២. អំពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ ភីភល ភីអិលស៊ី

## ២.១. ប្រវត្តិសង្ខេប

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ ភីភល ភីអិលស៊ី ហៅកាត់ថា(អេភី) បានចុះបញ្ជីពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជាជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលមានលេខអាជ្ញាប័ណ្ណ ០០០០៩៤២៩ ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០១១ និងទទួលអាជ្ញាបណ្ណអចិន្ត្រៃយ៍ពីធនាគារ ជាតិនៃកម្ពុជា (NBC) ដើម្បីធ្វើប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ រៀងមក។ បច្ចុប្បន្នគ្រឹះស្ថាន មានចំនួន ៣១ សាខា៖

**២០១១**

>ទទួលបានអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ពី ធនាគារជាតិនៃកម្ពុជា
>ចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ក្នុងនាម ជាក្រុមហ៊ុន មហាជនទទួលខុសត្រូវមានកម្រិត

**២០១២**

> បង្កើនដើមទុនពី ៣០០.០០០ ដុល្លារ ដល់ ៧៩១.៨០០ដុល្លារ
> ផ្លាស់ប្តូរទីតាំងថ្មី ដែលមានអាសយដ្ឋាន នៅផ្ទះលេខ ១៤៩ សេ ផ្លូវលេខ ១៤៣ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានី ភ្នំពេញ

**២០១៣**

> បង្កើនដើមទុនពី៧៩១.៨០០ដុល្លារ ដល់ ៥.០០១.៨០០ដុល្លារ
> ផ្លាស់ប្តូរទីតាំងថ្មី ដែលមានអាសយដ្ឋាននៅអាគារ លេខ ៣៥-៣៧ ផ្ទះលេខ ២១៤ សង្កាត់បឹងរាំង ខណ្ឌ ៧មករា រាជធានីភ្នំពេញ
> បង្កើតសាខាខេត្តសៀមរាប និងសាខាខណ្ឌ បឹងកេងកង៣

**២០១៤**

> បង្កើតសាខាខណ្ឌសែនសុខ

**២០១៥**

> បង្កើនដើមទុនពី៥.០០១.៨០០ ដុល្លារអាមេរិក ដល់ ៨.៥០១.៨០០ ដុល្លារអាមេរិក

**២០១៦**

>បង្កើនដើមទុនពី ៨.៥០១.៨០០ ដុល្លារ អាមេរិកដល់ ១០.០០១.៨០០ ដុល្លារ អាមេរិក
>បង្កើតសាខាខេត្តបាត់ដំបង និងសាខាខេត្ត កំពង់ចាម

## ២០១៧

> ផ្លាស់ប្តូរទីតាំងគឺស្នាក់ការកណ្តាលថ្មី ដែលមានអាសយដ្ឋាននៅ អាគារលេខ៨៨ ផ្លូវលេខ២១៤ កែងនឹងផ្លូវ១១៣ ភូមិ៤ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ

> បង្កើតសាខា ខេត្តកណ្តាល សាខាខេត្តតាកែវ និងសាខាខណ្ឌទួលគោក

## ២០១៨

> បង្កើតសាខាខណ្ឌមានជ័យ ខណ្ឌច្បារអំពៅ ខណ្ឌជ្រោយចង្វា ខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ស្ពឺ

## ២០១៩

> បង្កើតសាខាត្បូងឃ្មុំ និងខណ្ឌព្រែកព្នៅ

## ២០២០

> បង្កើតសាខាខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តក្រចេះ និងខេត្តរតនៈគិរី

>បង្កើនដើមទុនពី១០.០០១.៨០០ ដុល្លារអាមេរិក ដល់ ២០.០០០.០០០ ដុល្លារអាមេរិក

## ២០២១

>បង្កើតសាខា ស្រុកបារាយណ៍ ឃុំបល្ល័ង្គ (ខេត្តកំពង់ធំ), សាខាខេត្តព្រះវិហារ, សាខាខេត្តឧត្តរមានជ័យ,សាខាខណ្ឌដង្កោ,សាខាខណ្ឌពោធិ៍សែនជ័យ,សាខាខេត្តកំពត ,សាខាក្រុងប៉ោយប៉ែត, សាខាខេត្តស្វាយរៀង, សាខាស្រុកពាមរក៍ ឃុំព្រែកខ្សាយ ខ(ខេត្តព្រៃវែង)

## ២០២៣

>បង្កើនដើមទុនពី២០.០០០.០០០ ដុល្លារអាមេរិក ដល់ ៥០.០០០.០០០ ដុល្លារអាមេរិក

## ២០២៥

> បង្កើតសាខា ខេត្តព្រះសីហនុ និងសាខាខេត្តពោធិ៍សាត់



# ២.២. ចក្ខុវិស័យ បេសកកម្ម ពាក្យស្លោក ក្រមអនុវត្ត គោលការណ៍ណែនាំ

## ក. ចក្ខុវិស័យ

យើងមានបំណងក្លាយទៅជាគ្រឹះស្ថានហិរញ្ញវត្ថុមួយ ឈានមុខគេ តាមរយៈការផ្តល់សេវាកម្មល្អប្រសើរ និងរីកចម្រើនប្រកបដោយស្ថេរភាព។



## គ. បេសកកម្ម

យើងធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា តាមរយៈការចូលរួម និងផ្តល់នូវឥណទានដោយប្រកាន់ខ្ជាប់ភាពជាដៃគូនៃអាជីវកម្មហិរញ្ញវត្ថុ ។



## ឃ. ពាក្យស្លោក

យើងស្តាប់លោកអ្នក គិតជាមួយលោកអ្នកដើម្បីបង្កើតដំណោះស្រាយដ៏ល្អបំផុតសម្រាប់ភាពជោគជ័យរបស់លោកអ្នក ។



## ខ. ក្រមអនុវត្ត

- **ការជៀសវាងបំណុលលើសលប់៖** គ្រឹះស្ថានផ្តល់ឥណទានតាមលទ្ធភាពសងរបស់អតិថិជន និងរកវិធីដើម្បីបញ្ចៀសបំណុលលើសលប់តាមដែលអាចធ្វើបាន។
- **ក្រមសីលធម៌របស់បុគ្គលិក៖** គ្រឹះស្ថានមានការបណ្តុះបណ្តាលបន្ថែម និងប្រកាន់ខ្ជាប់នូវឥរិយាបថប្រកបដោយការគោរព ក្រមសីលធម៌ខ្ពស់ ចំពោះអតិថិជនគ្រប់មជ្ឈដ្ឋានពីបុគ្គលិកគ្រប់លំដាប់ថ្នាក់។
- **សេរីភាពក្នុងការជ្រើសរើស៖** អតិថិជនមានសិទ្ធិជ្រើសរើសផលិតផល ឬសេវាកម្មរបស់គ្រឹះស្ថានដែលសមស្របនឹងមុខរបរ និងតម្រូវការ។
- **យន្តការឆ្លើយតបចំពោះមតិយោបល់៖** គ្រឹះស្ថានទទួលយកនូវមតិយោបល់ ដើម្បីស្តាបនា និងឆ្លើយតបឲ្យបានសមរម្យបំផុត។

## ច. គោលការណ៍ណែនាំ

- ផ្តល់សេវាហិរញ្ញវត្ថុជូនប្រជាពលរដ្ឋទូទៅដោយមិនប្រកាន់វណ្ណៈ
- ផ្តល់សេវាហិរញ្ញវត្ថុដែលមានលក្ខណៈបត់បែន និងងាយស្រួលជាងគេ
- ប្តេជ្ញាគោរព និងឲ្យតម្លៃអតិថិជនរបស់ខ្លួនជាអាទិភាព
- ប្តេជ្ញាប្រកាន់ខ្ជាប់នូវអត្តចរិកនិងស្តង់ដារការងារដើម្បីធានាបាននូវភាពជឿជាក់
- ប្តេជ្ញាផ្តល់សេវាកម្ម និងទំនាក់ទំនងល្អបំផុតដល់ប្រជាពលរដ្ឋគ្រប់រូប
- ជាគ្រឹះស្ថានរៀនសូត្រដែលមានការផ្លាស់ប្តូរ និងការចែករំលែកនូវព័ត៌មានសមស្របដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍



## ២.៣. ផលិតផលនិង សេវាកម្ម



១ កម្ចីរហ័ស

២ កម្ចីបង់រំលស់ម៉ូតូ

៣ កម្ចីបង់រំលស់គ្រឿងអេឡិចត្រូនិក

៤ កម្ចីប្រើប្រាស់ទូទៅ

៥ កម្ចីបង់រំលស់រថយន្ត

៦ កម្ចីបង់រំលស់ដី

៧ កម្ចីបង់រំលស់គ្រឿងចក្រកសិកម្ម

៨ ឥណទាន A-Plus

## ២.៤. បណ្តាញប្រត្តិបត្តិការ

### ក. ផលប័ត្រឥណទានសរុប (ដុល្លារអាមេរិក)

| | |
|---|---|
| ២០២៥ | ៥៧២,៥៨៨,១៤៨ |
| ២០២៤ | ៤៤៤,៥៣៦,៦៤៨ |
| ២០២៣ | ៣៣៨,១៧៤,០៣៩ |
| ២០២២ | ២៤៨,៦២០,៤៩៧ |
| ២០២១ | ១៤៨,៦១៣,៦១២ |

### ខ. ចំនួនអតិថិជន

| | |
|---|---|
| ២៨៣,៧៨៧ | ២០២៥ |
| ២៣៦,៣៦៥ | ២០២៤ |
| ១៩៩,៨៧៤ | ២០២៣ |
| ១៧៨,១៦២ | ២០២២ |
| ១៣៩,៨៧៩ | ២០២១ |

## គ. ទីស្នាក់ការ និងសាខាធ្វើប្រតិបត្តិការរបស់គ្រឹះស្ថាន




### ទីតាំងនៅរាជធានីភ្នំពេញ

- ទីស្នាក់ការកណ្ដាល
- សាខា ខណ្ឌបឹងកេងកង
- សាខា ខណ្ឌសែនសុខ
- សាខា ខណ្ឌទួលគោក
- សាខា ខណ្ឌច្បារអំពៅ
- សាខា ខណ្ឌមានជ័យ
- សាខា ខណ្ឌជ្រោយចង្វារ
- សាខា ខណ្ឌព្រែកព្នៅ
- សាខា ខណ្ឌដង្កោ
- សាខា ខណ្ឌពោធិ៍សែនជ័យ

# ៣.អភិបាលកិច្ចសាជីវកម្ម

## ៣.១. រចនាសម្ព័ន្ធ






នាយកដ្ឋានរដ្ឋបាល

# ៣.២. ក្រុមប្រឹក្សាភិបាល



**លោក Ryosuke KATAOKA**
ប្រធានក្រុមប្រឹក្សាភិបាល



**លោក Tatsuhiro KURIHARA**
សមាជិកក្រុមប្រឹក្សាភិបាល



**លោក Nobuhito KIKUCHI**
សមាជិកក្រុមប្រឹក្សាភិបាល/ អគ្គនាយក



**លោក Masao SUGITA**
សមាជិកក្រុមប្រឹក្សាភិបាល



**លោក ម៉ាឡាយ ខេមសូលី**
សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ/
ប្រធានគណៈកម្មការហានិភ័យ និងប្រតិបត្តិតាម



**លោកស្រី ស៊ិន ស៊ីឡៃន**
សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ/
ប្រធានគណៈកម្មការសវនកម្ម

# ៣.៣. គណៈគ្រប់គ្រងជាន់ខ្ពស់



លោក Nobuhito KIKUCHI
អគ្គនាយក



លោក សុន គឹមសា
នាយកប្រតិបត្តិ ប្រតិបត្តិការ



លោកស្រី ជា ធិតា
នាយិកានាយកដ្ឋានប្រតិបត្តិតាម



លោក កែ វុទ្ធី
នាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុង



កញ្ញា សេង ចាន់ដា
នាយិកានាយកដ្ឋានហិរញ្ញវត្ថុ



លោក Ishikawa MASAKI
នាយកនាយកដ្ឋានរដ្ឋបាល



លោក Ishii YUSUKE
នាយកនាយកដ្ឋានព័ត៌មានវិទ្យា



លោក Umezawa YASUHIRO
នាយកនាយកដ្ឋានគាំទ្រការគ្រប់គ្រងប្រមូលឥណទាន

# ៣.៤. គណៈគ្រប់គ្រងនាយកដ្ឋានប្រតិបត្តិការ



**លោក សុន គឹមសា**
នាយកប្រតិបត្តិ ប្រតិបត្តិការ



**លោកស្រី ឈុន គុយយីម**
នាយិកាគណៈគ្រប់គ្រងសាខា



**លោក ឌឹម វណ្ណដា**
នាយកគណៈគ្រប់គ្រងសាខា

# ៤. សកម្មភាពសង្គម អប់រំ កីឡា និងសកម្មភាពផ្សេងៗ

## ក. សកម្មភាពមនុស្សធម៌ កាកបាទក្រហមកម្ពុជា

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ ភីភល បានឧបត្ថម្ភថវិកាជូនកាកបាទក្រហមកម្ពុជាក្នុងឱកាសខួបទី១៦២ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម និងខួបលើកទី ៧០ឆ្នាំ នៃកាកបាទក្រហមកម្ពុជាក្រោមមូលបទ "រួមគ្នាស្ម័គ្រចិត្ត ដើម្បីសហគមន៍មានសុខភាពល្អ និងមានភាពធន់នឹងអាកាសធាតុ" ។

យើងរួមគ្នាចូលរួមក្នុងសកម្មភាពមនុស្សធម៌ដើម្បីរួមចំណែកដោះស្រាយការលំបាក និងដើម្បីសុខុមាលភាពរបស់ប្រជាពលរដ្ឋរងគ្រោះ និងងាយរងគ្រោះបំផុតក្នុងប្រទេសកម្ពុជា។





## ខ. ការបរិច្ចាគឈាម

ការចូលរួមបរិច្ចាគឈាមក្រោមប្រធានបទ «បរិច្ចាគឈាម សង្គ្រោះជីវិត» រៀបចំឡើងដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា សមាគមធនាគារនៅកម្ពុជា និងមជ្ឈមណ្ឌលជាតិផ្តល់ឈាម។
"យើងរួមគ្នាបរិច្ចាគឈាមដើម្បីផ្តល់ក្តីសង្ឃឹមនិង សង្គ្រោះជីវិតជនរងគ្រោះ និងអ្នកជម្ងឺ"



## គ. ការបរិច្ចាគដល់ជនភៀសសឹក

យើងចូលរួមចំណែកបរិច្ចាគដល់ជនភៀសសឹកដែលបានកំពុងស្ថិតនៅក្នុងមណ្ឌលសុវត្ថិភាព។ អំណោយសប្បុរសធម៌នេះផ្តល់ជូនដើម្បីរួមចំណែកដល់ភាពលំបាករបស់ក្រុមគ្រួសារភៀសសឹកទាំងអស់គ្នា។




## ឃ.ការប្រកួតជើងឯក អត្តពលកម្មជនពិការ លើកទី៦ ឆ្នាំ២០២៥

ដើម្បីចូលរួមលើកកម្ពស់វិស័យកីឡាជនពិការនៅកម្ពុជា គ្រឹះស្ថានបានបង្ហាញពីការយកចិត្តទុកដាក់ខ្ពស់តាមរយៈការចូលរួមឧបត្ថម្ភដល់កីឡាករ កីឡាការនី ក្នុងព្រឹត្តិការណ៍ «ការប្រកួតជើងឯកអត្តពលកម្មជនពិការ លើកទី៦» ក្រោមកិច្ចសហការជាមួយអង្គការបេះដូងមាស។

ការរៀបចំនេះមិនត្រឹមតែមានគោលបំណងពង្រឹងសមត្ថភាពបច្ចេកទេសនិងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងវិស័យកីឡាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ជាសកម្មភាពដ៏មានអត្ថន័យ ក្នុងការគាំទ្រលើកទឹកចិត្តនិងផ្តល់តម្លៃដល់ជនមានពិការភាពក្នុងសង្គមដើម្បីឱ្យអត្តពលករអត្តពលការនីពិការភាពមានឱកាសបញ្ចេញសមត្ថភាព និងភាពអំណត់ព្យាយាមរបស់ខ្លួនក្នុងវិស័យកីឡាជាតិ។





## ង. កម្មវិធីប្រគល់រង្វាន់ជូនអតិថិជន

កម្រងរូបភាពអតិថិជនដែលបានឈ្នះរង្វាន់ពីកម្មវិធីចាប់ឆ្នោតផ្សងសំណាងជូនអតិថិជនដែលបានប្រើប្រាស់សេវាកម្មកម្ចី និងបង់រំលស់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ ភីភល ភីអិលស៊ី។




## ច. កម្មវិធីលៀងសាយភោជន

កម្មវិធីលៀងសាយភោជន ប្រារព្ធឡើងក្នុងគោលបំណង ថ្លែងអំណរគុណដល់ដៃគូសហការ ព្រមទាំងមានការប្រគល់ពានរង្វាន់ជូនដល់ដៃគូសហការឆ្នើមប្រចាំឆ្នាំ និងបង្កើនទំនាក់ទំនងល្អក្នុងការសហការជាដៃគូសហការអាជីវកម្ម ឱ្យកាន់តែមានភាពជិតស្និទ្ធ។











## ឆ. ការប្រកួតកីឡាប្រចាំឆ្នាំ

ទិដ្ឋភាពនៃព្រឹត្តិការណ៍ប្រកួតកីឡាប្រចាំឆ្នាំលើកទី០៩ ក្នុងឱកាសបង្កើនភាពស្និទ្ធស្នាល និងផ្សារភ្ជាប់ទំនាក់ទំនងក្នុងក្រុមគ្រួសារអាក់ទីវ ភីភល។







## ជ. កម្មវិធីជប់លៀងបុគ្គលិកប្រចាំឆ្នាំ

កម្មពិធីជប់លៀងបុគ្គលិកប្រចាំឆ្នាំ ដែលប្រារព្ធឡើង ដើម្បីលើកទឹកចិត្ត ព្រមទាំងអរគុណដល់បុគ្គលិកទាំងអស់របស់គ្រឹះស្ថាន ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចធ្វើឲ្យអាក់ទីវ ភីភល មានការរីកចម្រើនដល់សព្វថ្ងៃ។





### ឈ. ពានរង្វាន់ "The Next Global 100 Awards 2025”

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី មានមោទកភាពដែលទទួលបានពានរង្វាន់កិត្តិយសពី Global Banking and Finance Review ដែលជាការទទួលស្គាល់នូវការប្តេជ្ញាចិត្តដ៏មុតមាំក្នុងការផ្តល់ជូនសេវាកម្មហិរញ្ញវត្ថុស្របតាមតម្រូវការរបស់អតិថិជននិងការសម្រេចបាននូវលទ្ធផលដ៏ជោគជ័យ។






អាសយដ្ឋានផ្ទះលេខ៨៨ ផ្លូវលេខ២១៤ កែងនឹង១១៣ ភូមិ៤ សង្កាត់បឹងព្រលិត
ខណ្ឌ៧មករា រាជធានីភ្នំពេញ

#88, St.214 corner St.113, Sangkat Boeng Prolit, Khan 7 Makara, Phnom Penh

/Activepeople's MFI

www.apmfi.com.kh

081 828 666 / 071 828 6666